**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពត្រួតពិនិត្យ និងតាមដាន**
**លេខ: ០៣៣/០៧ កណ អ.ត.ត**

# កំណត់ហេតុ
# កិច្ចប្រជុំ
# ក្រុមការងារបច្ចេកទេសចម្រុះ សម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ

ឆ្នាំពីពាន់ប្រាំពីរ ខែ តុលា ថ្ងៃទី ដប់ប្រាំពីរ វេលាម៉ោងដប់បួន និងសាមសិបនាទី នៅសាលប្រជុំ B21 នៃទីស្តីការ គណៈរដ្ឋមន្ត្រី មានរៀបចំកិច្ចប្រជុំក្រោមអធិបតីភាពរបស់ឯកឧត្តម **សំ សុខផល** ប្រធានក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីពិនិត្យ និងពិភាក្សាបន្តលើកិច្ចការរបស់ក្រុមការងារបច្ចេកទេសចម្រុះសម្រាប់កំណែទម្រង់ច្បាប់ និង តុលាការ ។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **សំ សុខផល** បានថ្លែងអំណរគុណដល់ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រី អ្នកនាងកញ្ញា ដែលជាតំណាងក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍មួយចំនួន និង មន្ត្រីអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលបានអញ្ជើញ ចូលរួម ប្រជុំក្នុងថ្ងៃនោះ ។ ជាបន្ទាប់ឯកឧត្តម បានមានប្រសាសន៍ថា កិច្ចប្រជុំថ្ងៃនេះ គឺដើម្បីពិនិត្យមើល និង តាមដានជាបន្តទៅលើសូចនាករតាមដានរួម ( JMI )ដែល ពាក់ព័ន្ធដល់កំណែទម្រង់ច្បាប់ និងតុលាការ ។

ក្នុងពេលនោះ ឯកឧត្តមបានធ្វើសេចក្តីរាយការណ៍នូវរបាយការណ៍ សង្ខេបស្តីពីស្ថានភាពច្បាប់ជាមូលដ្ឋានទាំងឡាយ ដែលជាសូចនាករតាមដានរួម ដូចដែលបានចែកជូនអង្គប្រជុំទាំងមូល។ ក្នុងនោះ មានលើក ឡើងពីច្បាប់ជាមូលដ្ឋានដូចតទៅ ៖

- ក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានអនុម័តរួចហើយ
- ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានអនុម័តហើយ

- សេចក្តីព្រាងក្រមរដ្ឋប្បវេណី ត្រូវបានសភាអនុម័តហើយ នៅសល់តែក្រមព្រហ្មទណ្ឌមិនទាន់អនុម័ត ហើយទាក់ទងនឹងក្រមព្រហ្មទណ្ឌនេះ ឯកឧត្តមមានជំនឿជឿជាក់ថា ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងជួយជំរុញក្រមនេះឱ្យបានឆាប់រហ័ស។
- ទាក់ទងនឹងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា សេចក្តីព្រាងនេះត្រូវបានពិនិត្យរួចហើយ ហើយក៏បានបញ្ជូនទៅអគ្គលេខាធិការរាជរដ្ឋាភិបាលតាំងពីខែសីហា ឆ្នាំ ២០០៧ មកម្ល៉េះ។
- ទាក់ទងនឹងសេចក្តីព្រាងច្បាប់ចាត់តាំងតុលាការ និងច្បាប់ពិសោធនកម្ម ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម កំពុងតែព្រាងនៅឡើយ ហើយឯកឧត្តមបានឃើញរបាយការណ៍របស់ដៃគូអភិវឌ្ឍន៍ កាលពីខែកញ្ញាកន្លងមកនេះ បានរាយការណ៍ថា សេចក្តីព្រាងច្បាប់ចាត់តាំង តុលាការនេះ ក្រុមប្រឹក្សាអ្នកច្បាប់កំពុងតែពិនិត្យឡើងវិញ។ បញ្ហានេះឯកឧត្តមបានបដិសេធថា ក្រុមប្រឹក្សាអ្នកច្បាប់ពុំទាន់បានទទួលសេចក្តីព្រាងច្បាប់នេះនៅឡើយទេ។
- ចំពោះច្បាប់ប្រឆាំងអំពើពុករលួយ គឺកំពុងស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានពីក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច។

ឯកឧត្តមបានជម្រាបជូនជាព័ត៌មានថា ឯកឧត្តមបានទទួលលិខិតមួយច្បាប់ ពីឯកឧត្តមប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ កាលពីដើមខែតុលា ស្តីអំពីការស្នើសុំយោបល់ពីរាជរដ្ឋាភិបាលក្នុង ការគាំទ្ររបស់ភាគីបារាំងក្នុងការជួយធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋបាល និងក្រមរដ្ឋបាល ហើយឯកឧត្តម ក៏បានពិនិត្យរួមគ្នាជាមួយឯកឧត្តម **ស៊ុយ ម៉ុងលាង** ហើយឯកឧត្តមសង្ឃឹមថា អគ្គរាជទូតបារាំងអាចនឹងទទួលយកសំណើនេះដាក់ជូនទៅរដ្ឋាភិបាលបារាំង។ ឯកឧត្តមបានអះអាងថា ទោះបីជាយ៉ាងណាក៏ក្រុមការងាររបស់ឯកឧត្តមជាមួយនឹងអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ នឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយភាគីបារាំងក្នុងការធ្វើក្រមទាំងពីរនេះ។ ជាបន្ទាប់ ឯកឧត្តមបានជម្រាបជូនផងដែរថា ក្នុងចំណោមច្បាប់ចំនួន១១៨ ដែលបានបញ្ជូនទៅរដ្ឋសភា ក្នុងនោះមាន ១០៥ ច្បាប់ដែលរដ្ឋសភាធ្វើការអនុម័តរួចហើយ។

ទាក់ទងនឹងរបៀបវារៈទីបី ស្តីពីរបាយការណ៍នៃភាពជឿនលឿនរបស់អនុក្រុមការងារបច្ចេកទេស ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានមានប្រសាសន៍ថ្លែងអំណរគុណដល់តំណាងក្រុមទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញការងារ។ ជាបន្ទាប់អនុក្រុមនីមួយៗធ្វើការរាយការណ៍ដូចតទៅ។

លោកស្រី Kate Elliott, AusAid បានចូលរួមអបអរសាទរដល់រាជរដ្ឋាបាលកម្ពុជា ដែលបានទទួលនូវការអនុម័តច្បាប់មូលដ្ឋានទាំងឡាយដែលឆ្លុះបញ្ចាំងតាមរយៈនៃការប្រជុំ GDCC កន្លងទៅនេះ ហើយលោកស្រីបានទទួលស្គាល់នូវការរីកចំរើនទាំងប៉ុន្មានដែលអនុក្រុមនីមួយៗ អនុវត្តការងារបានយ៉ាងគាប់ប្រសើរក្នុងពេលបច្ចុប្បន្ននេះ មិនតែប៉ុណ្ណោះលោកស្រីបានសន្យាថា នឹងធ្វើការចូលរួមសហការបន្ថែមទៀត ជាមួយរាជរដ្ឋាភិបាលកម្ពុជា។

ឯកឧត្តម **សំ សុខផល** បានថ្លែងអំណរគុណដល់តំណាង AusAid ភាគីបារាំង និង JICA ក្នុងការជួយលើច្បាប់ជាមូលដ្ឋានធំៗទាំងពីរជាបន្ទាប់ ឯកឧត្តមប្រធានបានស្នើសុំឱ្យអនុក្រុមធ្វើការរាយការណ៍ជាបន្តៗ។

លោក **សុង រ៉ាន់ស៊ីន** តំណាងមកពីសហគមន៍អឺរ៉ុប(EU) តំណាងឱ្យអ្នកសម្របសម្រួលអនុក្រុមទី១ លោកបានធ្វើការរាយការណ៍ជូនអង្គប្រជុំថា ការងារអនុក្រុមទី១នេះ ផ្តោតទៅលើការងារធ្វើបច្ចុប្បន្នភាពនៃគម្រោង(Updating Project Profile) ហើយលោកបានធ្វើរបាយការណ៍ស្តីអំពីតារាងMatrix ដែលទាក់ទងនឹងបញ្ហាធ្វើគម្រោងដូចខាងក្រោម៖

- **ផែនការសកម្មភាពរយៈពេលខ្លី ៖**
  - សកម្មភាពរយៈពេលខ្លី ១.១.៤ ដែលទាក់ទងនឹងកម្មវិធីសិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជា លោកបានទទួលរបាយការណ៍ពីខាងក្រសួងអប់រំអំពីកម្មវិធីសិទ្ធិមនុស្ស និងពលរដ្ឋវិជ្ជានេះថា បានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សានៅតាមសាលាហើយ។
  - សកម្មភាពរយៈពេលខ្លី ១.២.៣ យើងបានដាក់បញ្ចូលគ្នាជាមួយសកម្មភាពរយៈពេលខ្លី ១.២.២ ប៉ុន្តែចំណុចនេះមិនទាន់មានដៃគូអភិវឌ្ឍន៍ចូលរួមទេ។
  - ផែនការសកម្មភាពរយៈពេលខ្លី ១.៤.៥ បានដាក់បញ្ចូលជាមួយចំណុច ១.៤.១ រង់ចាំការជួយគាំទ្រពីដៃគូអភិវឌ្ឍន៍
  - ចំណុច ១.៤.៦ ដែលទាក់ទងនឹងក្រសួងកិច្ចការនារីពុំទាន់គ្រប់គ្រាន់នៅឡើយទេ ដោយមិនទាន់បានបង្កើតការិយាល័យប្រឆាំងបទរំលោភសេពសន្ធវៈ ហើយមិនទាន់មានដៃគូអភិវឌ្ឍន៍ចូលរួមដែរ។
- **ផែនការសកម្មភាពរយៈពេលមធ្យម ៖**
  - ចំណុច ១.១.១ បានកំពុងតែអនុវត្តដោយមានការគាំទ្រពីខាង UNDP
  - ចំណុច ១.៤.២ ទាក់ទងនឹងការបង្កើតច្បាប់ របបសារព័ត៌មានក៏មិនទាន់មានដៃគូចូលរួមដែរ
  - ចំណុច ១.៥.១ ការបង្កើតប្រព័ន្ធសុរិយោដី និងសាការីបាននឹងកំពុងអនុវត្តសេចក្តីព្រាងច្បាប់ស្តីពីសារការី
  - ចំណុច ១.៦.២ ទាក់ទងនឹងវិទ្យាស្ថានឧក្រិដ្ឋវិជ្ជា ទើបតែបានពិភាក្សាមានផែនការជួបជាមួយ ក្រសួងយុត្តិធម៌ បន្ទាប់មកជួបជាមួយក្រសួងមហាផ្ទៃ និងចុងក្រោយរៀបចំកិច្ចប្រជុំរវាងក្រសួងទាំងពីរ ។

ជាបន្ទាប់លោកបានលើកឡើងនូវបញ្ហាប្រឈមមុខមួយចំនួនដែរក្នុងពេលបំពេញការងារនេះ ៖

-ចំណុចទី១-បណ្តាក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួនខកខានពុំបានចូលរួមប្រជុំ Sub-Group

-ចំណុចទី២-តើស្ថាប័នមួយណាទទួលខុសត្រូវទៅលើការងារនេះ ?

-ចំណុចទី៣-លោកយល់ឃើញថា មិនទាន់ឃើញមានអង្គការដៃគូអភិវឌ្ឍន៍ណាជួយលើការងារនេះទេ

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានថ្លែងអំណរគុណដល់អនុក្រុមទី១ផងដែរ ដែលបានធ្វើសេចក្តីរាយការណ៍នេះ ហើយឯកឧត្តមបានលើកឡើងអំពីបញ្ហាប្រឈមមុខរបស់អនុក្រុមទី១ គឺ ៖

ចំណុចទី១ ទាក់ទងនឹងក្រសួងស្ថាប័នចូលរួមពាក់ព័ន្ធ យើងគួរពិនិត្យមើលទៅលើឯកសារទស្សនៈវិស័យ និងយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាក់ស្តែងនៅក្នុងនោះ មានបង្ហាញសកម្មភាពនីមួយៗពីក្រសួងស្ថាប័នពាក់ព័ន្ធ ហើយនោះជាគំនិតរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ហើយនៅពេលដែលយើងបង្កើតជាអនុក្រុម សម្រាប់ការងារនេះយើងកាន់តែមានទស្សនៈយ៉ាងច្បាស់អំពីក្រសួងស្ថាប័នមួយណា ដែលទទួលខុសត្រូវលើបញ្ហាអ្វីខ្លះនោះ។ ឯកឧត្តមមានមតិយោបល់ថា ចំពោះភាពទទួលខុសត្រូវរបស់អនុក្រុមទី១នេះ គឺធ្វើយ៉ាងណាឱ្យក្រសួងស្ថាប័នពាក់ព័ន្ធនោះជាអ្នកទទួលខុសត្រូវ។

លោកស្រី Momoko Hotta (Assistant Resident Representative, JICA ) មានប្រសាសន៍ថា អនុក្រុមទី២ ក៏មានបញ្ហាប្រហែលគ្នានឹងអនុក្រុមទី១នោះដែរ ដូច្នេះលោកស្រីចង់ឱ្យមានការចូលរួមពីក្រសួងស្ថាប័នឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន។ លោកស្រីបានជម្រាបជូនអំពីផលវិបាកក្នុងការទំនាក់ទំនងគ្នាដោយពុំដឹងថា គួរទៅទាក់ទងជាមួយនឹងបុគ្គលណាមួយ នៅក្នុងក្រសួងស្ថាប័ន ឬក៏អង្គភាពណាមួយឱ្យពិតប្រាកដនោះទេ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានសុំអភ័យទោសផងដែរ ចំពោះការខ្វះខាតបញ្ហាទំនាក់ទំនងនោះ ហើយឯកឧត្តមសង្ឃឹមថា មន្ត្រីរបស់ឯកឧត្តមនឹងបញ្ជូនបញ្ជីឈ្មោះអ្នកដែលត្រូវធ្វើទំនាក់ទំនងជូនទៅលោកស្រីនៅពេលខាងមុខ។

លោកស្រី Momoko Hotta បានជម្រាបថា ការងារដែលសំខាន់ចំពោះអនុក្រុមទី២ ទាក់ទងទៅនឹងយុទ្ធសាស្ត្រទី២ គឺការធ្វើទំនើបកម្មក្របខណ្ឌច្បាប់ ទាក់ទងនឹងការងាររបស់អនុក្រុមទី២នេះ លោកស្រីបានធ្វើការចែកជូនជាឯកសារមួយចំនួនជូនអង្គប្រជុំរួចហើយដែរ។ លោកស្រីក៏បានលើកឡើងពីបួនចំណុចដ៏សំខាន់ៗ ដែលជាខ្លឹមសារក្នុងកិច្ចប្រជុំមួយរបស់អនុក្រុមទី២កាលពីថ្ងៃទី ២៨ កញ្ញា ឆ្នាំ ២០០៧ កន្លងមកថ្មីៗនេះគឺ ៖

ទី១- ការធ្វើបច្ចុប្បន្នភាព និងតារាងនៃភាពជឿនលឿនក្នុងយុទ្ធសាស្ត្រទី២

ទី២- ការធ្វើបច្ចុប្បន្នភាពនៃបញ្ជីច្បាប់

ទី៣- លទ្ធផលនៃការស្វង់មតិនៃអង្គភាពច្បាប់នៅតាមបណ្តាក្រសួងស្ថាប័ននានា

ទី៤- ទាក់ទងនឹងការចែករំលែកបទពិសោធន៍ល្អៗ ដែលទាក់ទងនិងការធ្វើច្បាប់ផ្សេងៗ។

លោក Rajan Shah (Access to Justice Advisor) EWMI តំណាងអនុក្រុមទី៤ បានធ្វើការបង្ហាញពីរបាយការណ៍សង្ខេបការងាររបស់លោក ដែលមានចែកជូនជាឯកសារស្រាប់ ក្នុងនោះមានជាតារាង (Chart) ដោយផ្តោតទៅលើយុទ្ធសាស្ត្រទី៤ និងយុទ្ធសាស្ត្រទី៥។ លោកបានបញ្ជាក់ផងដែរថា តារាងនោះមិនទាន់បានបញ្ចប់នៅឡើយទេ ហើយទាក់ទងនឹងយុទ្ធសាស្ត្រទី៤ ដែលពាក់ព័ន្ធនឹងការបង្កើតការិយាល័យអំប៊ូសមែន ដែលអនុក្រុមទី១បានលើកឡើងនោះ ដូចជាមិនទាន់ឃើញមានការរីកចំរើននៅឡើយដែរ។

លោកក៏បានជម្រាបបន្ថែមទៀតអំពីតារាង(Chart)នេះថា រាអាចវាស់វែងពីភាពជឿនលឿនរបស់ការងារអនុក្រុមទី៤ ហើយលោកបានស្នើសុំឱ្យមានការប្រជុំអនុក្រុម(Sub-Group)រាល់ពីរខែម្តង ពីព្រោះថា មន្ត្រីកំពូលរបស់ក្រសួងស្ថាប័ននីមួយៗមានការមមាញឹកខ្លាំងពេក។ លោកក៏ចង់ស្នើ សុំឱ្យមានមន្ត្រីមកពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចូលរួមផងដែរ។

ខាង AusAid ក៏មានការស្នើសុំខាង EWMI ធ្វើការបកប្រែក្រមនីតិវិធីព្រហ្មទណ្ឌទៅជាអង់គ្លេសដើម្បីងាយស្រួលដៃគូអភិវឌ្ឍន៍តាមដាន និងពិនិត្យមើលលើច្បាប់នេះ។

ឯកឧត្តម **ផៃ សុខខេង** ស្ថិតនៅក្នុងអនុក្រុមទី៤ បានចោទសួរថា នៅពេលប្រជុំក្រុមរបស់លោកលើកទី៦ តើអាចអញ្ជើញអង្គការសង្គមស៊ីវិល ឬអង្គការក្រៅរដ្ឋាភិបាលបានដែរឬទេ?

ឯកឧត្តម **សំ សុខផល** បានមានប្រសាសន៍ថា ទាក់ទងនឹងការចូលរួមពីសង្គមស៊ីវិល ឬក៏អង្គការក្រៅរដ្ឋាភិបាលនោះ ឯកឧត្តមមិនមានការជំទាស់ទេ។

ឯកឧត្តម **ស៊ុយ ម៉ុងលាង** បានឆ្លើយតបទៅនឹងសំណួរខ្លះរបស់លោកស្រី Momoko ដូចជាបញ្ហាទាក់ទងទៅនឹងបញ្ជីច្បាប់ និងការពង្រឹងអង្គភាពច្បាប់ ឯកឧត្តមបានគាំទ្រចំពោះអនុក្រុមទី២ ដែលបានបំពេញការងារប្រកបដោយភាពរីកចំរើន។ ចំពោះការខ្វះខាតក្នុងការចូលរួមរបស់ក្រសួង ស្ថាប័ននានា បញ្ហានេះអាស្រ័យទៅលើអនុក្រុមនីមួយៗអាចធ្វើបានរយៈពេល២ខែម្តង ប៉ុន្តែធ្វើយ៉ាងណាកុំឱ្យជាន់គ្នានិងការប្រជុំក្រុមការងារបច្ចេកទេសចម្រុះ។ ជាបន្ទាប់ ឯកឧត្តមបានលើកយកមកបង្ហាញ អំពីសកម្មភាពរីកចំរើនដែលទាក់ទងទៅនឹងយុទ្ធសាស្ត្រទាំង៧គឺ ៖

- យុទ្ធសាស្ត្រទី១ ស្តីពីទិន្នន័យនៃការបណ្តុះបណ្តាលសិទ្ធិមនុស្សគម្រោងមានការគាំទ្រដោយ UNDP ហើយឥឡូវនេះ យើងបានជួលអង្គការមួយដើម្បីរៀបចំទិន្នន័យរួចហើយ ។ គម្រោងនេះ ត្រូវបញ្ចប់នៅខែធ្នូ
- យុទ្ធសាស្ត្រទី២ ភាគច្រើនទាក់ទងនឹង JMI ចំណុចនេះមិនចាំបាច់លំអិតទេ
- យុទ្ធសាស្ត្រទី៣ គម្រោងនេះជួយដោយ UNDP និង French Cooperation។ គឺគម្រោងស្តីពីរាជកិច្ចរហូតមកដល់ពេលនេះភាគីបារាំង និងឯកឧត្តមផ្ទាល់បានកំពុងតាក់តែងអនុក្រឹត្យហើយ។ បន្ទាប់ពី អនុក្រឹត្យនេះចេញហើយ UNDP និងជួយខាងផ្នែកបច្ចេកទេសវិញម្តង
- យុទ្ធសាស្ត្រទី៥ ទាក់ទងនឹងការពង្រីកបន្ថែមតុលាការគំរូ ឯកឧត្តមបានជម្រាបជូនអង្គប្រជុំថា ដំណើរការការងារនេះក្នុងពេលនេះ គឺជាដំណាក់ការនៃការធ្វើការវិភាគលើការងារតុលាការ ដែលនឹងទៅជាតុលាការគំរូ។ គម្រោងនេះមានការគាំទ្រដោយ CCJAP III & DANIDA។
- យុទ្ធសាស្ត្រទី៦ មានគម្រោងមួយដែលផ្តល់ជំនួយដោយ UNDP ពាក់ព័ន្ធដល់ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

- យុទ្ធសាស្ត្រទី៧ មានគម្រោងមួយស្តីអំពីប្រព័ន្ធសូចនាករ ហើយក្នុងនោះក៏មានការបង្កើតក្រុមការងារធ្វើការងារនេះដែរ រាជរដ្ឋាភិបាលក៏ចង់ឱ្យមានការចូលរួមពីសំណាក់ដៃគូអភិវឌ្ឍន៍ឱ្យច្រើនផងដែរ។

ខាង AusAid បានមានប្រសាសន៍ថា ទាក់ទងនឹងគម្រោងនៃការបង្កើតតុលាការគំរូនេះ ខាង AusAid & CCJAP III កំពុងតែរៀបចំបែងចែកធនធាន ហើយលោកស្រីបានស្នើសុំឱ្យមានការលើកឡើងអំពីបញ្ហា Gender ក្នុង របៀបវារៈនៃកិច្ចប្រជុំ TWG លោកក្រោយ។

លោក Rajan Shah បានឯកភាពទៅលើការដាក់ប្រធានបទ Gender ក្នុងកិច្ចប្រជុំTWG នេះផងដែរ។

លោកជំទាវ **សម ម៉ូនីកា** អគ្គនាយករងក្រសួងកិច្ចការនារី បានជម្រាបថា បញ្ហា Gender នេះ ខាងក្រសួងកិច្ចការនារីបានធ្វើការងារយ៉ាងល្អ ដែលទាក់ទងនឹងក្រសួងជាច្រើន ហើយលោកជំទាវបានជម្រាបផងដែរថា ពេលប្រជុំលើកក្រោយលោកជំទាវនឹងរៀបចំជារបាយការខ្លីៗជូនអង្គប្រជុំ។

ទីបញ្ចប់ ឯកឧត្តម **សំ សុខផល** បានថ្លែងអំណរគុណចំពោះការចូលរួមពិគ្រោះយោបល់ក្នុងអង្គប្រជុំទាំងមូល និងសម្រេចថា កិច្ចប្រជុំនេះនឹងបន្តធ្វើនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៧ ខាងមុខនេះ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងបួន និងសែសិបប្រាំនាទីល្ងាចនាថ្ងៃដដែល។

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០៧*

**ឧត្តមលោ ១ និងឯកភាព**
**នាយកអង្គភាពគ្រប់គ្រងគម្រោង** **អ្នកធ្វើរបាយការណ៍**

**ស៊ុយ ម៉ុងណាង** **សេង រ៉ាន់ដា** **ស៊ុន សិរីតុធ**

# បញ្ជីឈ្មោះសមាសភាពចូលរួមក្នុងកិច្ចប្រជុំពិភាក្សា
# នាថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៧

០១-ឯកឧត្តម សំ សុខផល ប្រធានក្រុមការងារបច្ចេកទេសចម្រុះ
០២-ឯកឧត្តម ស៊ីយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៣-ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងអង្គភាពគ្រប់គ្រងគម្រោង ក.ក.ច.ន.យ
០៤- លោកជំទាវ ចាន់ សុទ្ធារី អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
០៥-លោកជំទាវ សម មូនីកា អគ្គនាយករងក្រសួងកិច្ចការនារី
០៦-ឯកឧត្តម ផៃ សុខខេង ប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ ក.ក.ច.ន.យ
០៧-លោក ជឹង ផេងស្រូយ ប្រធានក្រុមគម្រោងបណ្ណ័ាសារ និងព័ត៌មានវិទ្យា ក.ក.ច.ន.យ
០៨-កញ្ញា ជាន់ ពីសីនលក្ខណ៍ មន្ត្រី ក.ក.ច.ន.យ
០៩-លោក កូយ សៅ អនុប្រធានក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
១០-លោកស្រី ឈូក សារ៉ុម មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១១-លោក ស៊ុន សិរីវុធ មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១២-លោក ជ សៀកវ៉ែង CCJAPIII
១៣-លោក គង់ ផល្លៈ អនុប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
១៤-លោកស្រី យិន កក្កដា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១៥-លោក ផែ លី អនុប្រធានក្រុមគម្រោងកំណែទម្រង់តុលាការ ក.ក.ច.ន.យ
១៦-លោក ឆុង ហួត ប្រធានក្រុមគម្រោងកំណែទម្រង់ច្បាប់ ក.ក.ច.ន.យ
១៧-លោក ហូរ ភក្ត្រា មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១៨-លោក សួន រ៉ៃ: មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ក.ក.ច.ន.យ
១៩-លោក ឃ្លោក ដារ៉ា ប្រធាន ក្រុមគម្រោងសិទ្ធិមនុស្ស និងមជ្ឈត្តកម្ម
២០-លោកស្រី ស្រី ប៊ុណ្ណារ៉ត្ន
២១- Kheang Seng, AGU
២២- Momoko Hotta (Assistant Resident Representative, JICA )
២៣- Mr. Real Sophen, Ministry of Interror
២៤- Seng Rethy, ( Legal Assistant ) Lawyer

២៥- Po Phalla ( Vice Director Of Law enforcement Of Anti Corruption Unit )

២៦- Mr. Pierre Espieu, Chef de project, Appui à L' Etat de Droit, France

២៧- Song Vannsin, EU

២៨- Hermoso Elise Chargeede Mission French Corporation

២៩- Mr. Rajan Shah (Access to Justice Advisor) EWMI

៣០- Saku Shiotani ( Staff Of JICA)

៣១--Kana Manabe (Legal Advisor) MOJ/JICA

៣២- Bertrand Stephanie ( Embassy Of France)

៣៣-Steuma Izumi Mochizuki ( Third Secretary Embassy Of Japan )

៣៤- Heusile Steuman ( OHCHR )

៣៥- Lesley Miller ( UNICEF Chief Child Protection )

៣៦- Michael Engquist ( Governance consultant Danida )

៣៧- Phon Samphors (Deputy Director CDC/CRDB

៣៨- Kate Elliott (Second Secretary AUSAID )